# English for Study in Australia
## កម្មវិធីភាសាអង់គ្លេសសម្រាប់ការសិក្សានៅប្រទេសអូស្ត្រាលី

LESSON 21– Calling for help

**មេរៀនទី២១ ៖ ការសុំជំនួយ**

**STUDY NOTES**

ឯកសារជំនួយមេរៀន

**<u>តួអង្គ</u>**

Rocky:
រ៉ុកឃី៖ និស្សិតបរទេស។

John:
ចន៖ និស្សិតបរទេសសិក្សានៅសកលវិទ្យាល័យ។

Angel:
អែនជល៖ និស្សិតបរទេស។

Katie:
ខេតធី៖ និស្សិតបរទេស។

Operator: ប្រតិបត្តិក(ប្រតិបត្តិករសម្រាប់លេខទូរស័ព្ទសង្គ្រោះបន្ទាន់)

**<u>សាច់រឿង</u>**

និស្សិតទាំង៤នាក់ កំពុងធ្វើដំណើរទៅស្នាក់នៅឯសួនខារ៉ាវ៉ាន នៅឧទ្យានជាតិ Grampians ដែលជាជួរភ្នំដ៏ល្បីល្បាញ និងមានលក្ខណៈពិសេស នៅរដ្ឋវិកថូរៀ។ ចន ប្រើឡានចាស់របស់គាត់ដឹកមិត្តភក្តិទាំងអស់គ្នា។

**<u>ព័ត៌មាន-សម្ភារៈចាំបាច់សម្រាប់ការបោះជំរំ</u>**

*ទាំងនេះគឺជាបញ្ជីរាយមុខរបស់របរ ដែលលោកអ្នកនឹងត្រូវការសម្រាប់ដំណើរបោះជំរំប្រកបដោយសុវត្ថិភាព។*

- ទឹកដប ឬសម្ភារៈបន្សុទ្ធទឹក
- កូនកាំបិតសម្រាប់ដាក់តាមខ្លួន
- តង់ស្រាល
- សម្ភារៈសម្រាប់គេង(sleeping bag)
- ឧបករណ៍សម្រាប់បង្កាត់ភ្លើង ដូចជា ឈើគូស ដែកកេះ។ល។
- សម្លៀកបំពាក់២-៣ជាន់
- ក្រដាសបង្គន់អនាម័យ
- អាហារសម្រាប់បោះជំរំ-ជាការប្រសើរបំផុត ប្រសិនបើអាចនាំយកអាហារចម្អិនស្រាប់ ឬដែលងាយចម្អិន
- ផ្ទាំងសំពត់ឬកៅស៊ូដែលមិនជ្រាបទឹក


© RadioAustralia/AMES 2008

- ឧបករណ៍បំភ្លឺ-ប្រភពដែលប្រសើរបំផុត គឺភ្លើងពិលពាក់លើថ្ងាស ដែលអាចប្រើ នៅពេលលោកអ្នកប្រើដៃទាំងពីសម្រាប់ធ្វើកិច្ចការអ្វីផ្សេងទៀត។
- ក្រែមបង្ការកម្តៅថ្ងៃ-ដាច់ខាតត្រូវតែយកទៅតាមខ្លួន
- ចំណីញ៉ាំសម្រន់ការឃ្លានឬកំជរមាត់-ផ្លែឈើក្រៀម និងសណ្តែកដី ជាចំណីងាយវេចខ្ចប់ និងរក្សាទុកបានយូរ
- ផែនទី
- ប្រដាប់ប្រដាសម្រាប់ចម្អិន និងសម្ភារៈប្រើសម្រាប់ដាក់ឬទទួលទានអាហារ
- ថង់យាម -ក្រែមបង្ការកម្តៅថ្ងៃ ម៉ាស៊ីនថតរូប និងអាហារសម្រន់ ។ល។
- ថង់ផ្លាស្ទិកសម្រាប់ដាក់សំរាម និងសម្រាប់ព្យួរអាហារទុកនៅមែកឈើ
- ស្រោមជើងច្រើនគូ
- ម៉ាស៊ីនថតរូប
- ទូរស័ព្ទដៃ
- កញ្ចក់ និងកញ្ចែ ៖ ចំណាំងប្លាតព្រះអាទិត្យនៅលើកញ្ចក់ អាចធ្វើឱ្យអ្នកខាងក្រៅមើលឃើញក្នុងចម្ងាយរហូតដល់ទៅ១០០គីឡូម៉ែត្រ ហើយសំឡេងរបស់កញ្ចែអាចជួយបំពងសំឡេងឱ្យឮខ្លាំងជាងសំឡេងធម្មតារបស់មនុស្សឆ្ងាយណាស់។

## <u>ភាសា-សំនួនវោហារ និងឃ្លាប្រយោគដែលមានន័យមិនធម្មតា</u>

| | |
|---|---|
| To rough it | រស់នៅដោយមិនមានផាសុកភាពដូចសព្វមួយដង។ |
| Roadside assistance | សេវាជាងជួសជុលរថយន្ត ដែលនឹងទៅជួយលោកអ្នកប្រសិនបើរថយន្តរបស់លោកអ្នកខូច។ |
| Aboriginal | សំដៅដល់ជនជាតិដើមភាគតិចនៅក្នុងប្រទេស។ ជនជាតិដើមភាគតិចអូស្ត្រាលី។ |


© RadioAustralia/AMES 2008

# លំហាត់

## ១. វាក្យសព្ទសំខាន់ៗ

សូមផែកអត្ថន័យ និងការបញ្ចេញសំឡេងនៃពាក្យទាំងអស់នេះនៅក្នុងវចនានុក្រមរបស់លោកអ្នក៖

| | | |
|---|---|---|
| (to) borrow | camp | caravan |
| cave | (to) climb | instruction |
| park | site | sleeping bag |
| tent | tyre | unconscious |

## ២. ការហាត់រៀនភាសា លំហាត់គំរូ តេស្តស្ទង់កម្រិតសមត្ថភាពភាសាអង់គ្លេស

ដើម្បីអាចចូលរៀនក្នុងវគ្គសិក្សាណាមួយនោះ លោកអ្នកត្រូវធ្វើតេស្តដើម្បីស្ទង់កម្រិតសមត្ថភាពភាសាអង់គ្លេសជាមុនសិន។ សូមកត់ចំណាំថា ការណែនាំក្នុងការធ្វើតេស្ត ជាទូទៅសរសេរជាភាសាអង់គ្លេស (ដូចខាងក្រោម)។

Choose the word that best fits each space in the text below.
ចូរជ្រើសពាក្យដែលស័ក្តិសមបំផុតសម្រាប់ដាក់ទៅក្នុងចន្លោះនៃអត្ថបទក្នុងប្រអប់ខាងក្រោម។

Cross one box for each number, eg: ☒
ចូរគូសខ្វែងក្នុងប្រអប់មួយនៃលេខនីមួយៗ។ ឧទាហរណ៍ ☒

**The Grampians**

The Grampians National Park (also known by its Aboriginal name, “Gariwerd”) is located in the western district ______1______Victoria. It covers 167,000 acres and is a safe haven ______2______ many species of Australian animals, such ______3______ koalas and kangaroos. It is a very popular park for tourists. You can ______4______ stunning rock formations and native forests and wildlife. During the spring, ______5______ the wildflowers come out, the park is a spectacle of colour.

| | | | | |
|---|---|---|---|---|
| 1. | ☐ of | ☐ at | ☐ into | ☐ up |
| 2 | ☐ for | ☐ and | ☐ because | ☐ so |
| 3. | ☐ is | ☐ are | ☐ be | ☐as |
| 4 | ☐ look | ☐ see | ☐ looking | ☐ come |
| 5 | ☐ when | ☐ why | ☐ through | ☐ with |


© RadioAustralia/AMES 2008

## ៣. ឧបសគ្គក្នុងការប្រើប្រាស់ភាសា

**សូរសំឡេង / r / និង / l /** ៖ សូមហាត់រៀនពាក្យដែលត្រូវប្រឹងពត់អណ្តាតរួចបញ្ចេញសំឡេងឲ្យបានឮៗ ៖

**"The lovely lambs ran around the rolling hills."**

## ៤. អាសយដ្ឋានអ៊ីនធើរណិតដែលមានប្រយោជន៍

| | |
|---|---|
| ព័ត៌មាន ៖ ឧទ្យានជាតិនៅប្រទេសអូស្ត្រាលី | http://www.australia.com/Search.aspx?q=National%20Parks%20&cat=ALL |
| អំពីសេវាសង្គ្រោះបន្ទាន់អូស្ត្រាលី | http://www.australiatravelsearch.com.au/trc/emergency.html |
| សេវាផ្តល់ជំនួយជាងរថយន្តនៅពេលមានបញ្ហាតាមផ្លូវ | South Australia: http://www.raa.net/<br>Victoria: http://www.racv.com.au/wps/wcm/connect/Internet/Primary/home<br>Western Australia: http://rac.com.au/go/motoring/roadside-assistance<br>Tasmania: http://www.ract.com.au/<br>Queensland: http://www.racq.com.au/cps/rde/xchg/racq_cms_production/hs.xsl/homepage_ENA_HTML.htm<br>NSW: http://www.mynrma.com.au/cps/rde/xchg/mynrma/<br>Northern Territory: http://www.aant.com.au/ |
| រូបភាពនៃឧទ្យានជាតិ Grampians | http://members.virtualtourist.com/vt/s/?i=1&s=&m=6&l.l=1c9ee9&t= |

ចម្លើយលំហាត់ទី 2: 1) of 2) for 3) as 4) see 5) when

ABC Radio Australia
radioaustralia.net.au
AMES
www.ames.net.au
© RadioAustralia/AMES 2008